# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២២-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ១៦១៩

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១៧-៣-២០០៦ -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពីការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បរិវេណដីនៅក្រុងព្រះសីហនុ សម្រាប់ការអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិកងកេង និងហេដ្ឋារចនាសម្ព័ន្ធចំណុះ ១៦២០

១៦-៣-២០០៦ -អនុក្រឹត្យលេខ ១៧៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៦២៣

១៦-៣-២០០៦ -អនុក្រឹត្យលេខ ១៧៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៦២៥

១៧-៣-២០០៦ -អនុក្រឹត្យលេខ ១៧៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦២៧

១៧-៣-២០០៦ -អនុក្រឹត្យលេខ ១៧៨ អនក្រ.តត ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ១៦២៨

២៣-៣-២០០៦ -អនុក្រឹត្យលេខ ១៧៩ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្រ្តីរាជការ ១៦៣០

### ២-សេចក្តីសំរេច

២០-៣-២០០៦ -សេចក្តីសំរេចលេខ ០៨ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ១៦៣១

២៣-៣-២០០៦ -សេចក្តីសំរេចលេខ ០៩ សសរ ស្តីអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ១៦៣២

### ៣-សារាចរ

១៨-៣-២០០៦ -សារាចរលេខ ០២ សរ ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់រថយន្តចង្កូតស្តាំដែលមានស្រាប់នៅក្នុងប្រទេស ១៦៣៥

## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២២-៣-២០០៦ -ប្រកាសលេខ ៣៣៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **អ៊ីជា កុំព្យូទ័រ អ៊ីមប្រូឌើរ** បង្កើតសាខារោងចក្រ " ប៉ាក់សម្លៀកបំពាក់ " ដែលមាន ឈ្មោះថា " អ៊ីជាកុំព្យូទ័រ អ៊ីមប្រូឌីរ សាខាទី ១" ១៦៣៧

២២-៣-២០០៦ -ប្រកាសលេខ ៣៣៧ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **អ៊ីជា កុំព្យូទ័រ អ៊ីមប្រូឌើរ ខូ អិលធីឌី** បង្កើតរោងចក្រ " ប៉ាក់សម្លៀកបំពាក់ " ដែលមាន ឈ្មោះថា " អ៊ីជា កុំព្យូទ័រ អ៊ីមប្រូឌីរ ខូ អិលធីឌី " ១៦៣៩

២៣-៣-២០០៦ -ប្រកាសលេខ ៣៤៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ីរីធន អ៊ិនដាសស្ត្រៀល ហ្គាមេន** បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ស៊ីរីធន អ៊ិនដាសស្ត្រៀល ហ្គាមេន " ១៦៤១

២៣-៣-២០០៦ -ប្រកាសលេខ ៣៤៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ហ៊ីង អ៊ី នីតធីង ហ្វេកធើរី កូ អិលធីឌី** បង្កើតរោងចក្រ " ចាក់សម្លៀកបំពាក់ " ដែលមានឈ្មោះថា " ហ៊ីង អ៊ី នីតធីង ហ្វេកធើរី កូ អិលធីឌី " ១៦៤៣

### ២~ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២០-៣-២០០៦ -ប្រកាសលេខ ១១៦ ប្រក.កសក.ប ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ១៦៤៥

### ៣~ទីស្តីការរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១៥-៣-២០០៦ -ប្រកាសលេខ ១៥៣ ស.អ.យ ស្តីពីនីតិវិធីកំណត់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការ ១៦៥៣

### ៤~ទីស្តីការរដ្ឋមន្ត្រី ក្រសួងការពារជាតិ

២៣-៣-២០០៦ -ប្រកាសលេខ ០១៣ /ប្រ.ក/២០០៦ ស្តីពីការកំណត់កាំបៀវត្សរ៍ និងប្រាក់ឧបត្ថម្ភបន្ថែមជូនកងកម្លាំងបំពេញបេសកកម្មបោសសំអាតមីននៅប្រទេសស៊ូដង់ ១៦៦២

### ៥~ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

០៤-០១-២០០៦ -លិខិតលេខ ០៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អ៊ុង ម៉ូធ័រសាយឃល គ្រុប** ១៦៦៥

០៥-០១-២០០៦ -លិខិតលេខ ០៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្លង់ សុផល្លា ខូ អិលធីឌី** ១៦៦៧

០៥-០១-២០០៦ -លិខិតលេខ ០៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **វើលវ៉ាយដ៍ ស៊ីបភីង ខូ អិលធីឌី** ១៦៦៩

០៥-០១-២០០៦ -លិខិតលេខ ០៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធី ជេ អេច ខ្មែរ ខបភើរេសិន លីមិធីត** ១៦៧១

០៥-០១-២០០៦ -លិខិតលេខ ០៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អាលទី ហ្វ័រវើឌីង ភីធីអ៊ី អិលធីឌី** ១៦៧៣

០៥-០១-២០០៦ -លិខិតលេខ ០៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្គោរអ៊ីង អ៊ិនធើណេសិនណាល** ១៦៧៥

០៥-០១-២០០៦ -លិខិតលេខ ០៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ត្រី សោភា អ៊ីមផត អិចផត (ខេ.អេស.ភី)** ១៦៧៧

០៥-០១-២០០៦ -លិខិតលេខ ០៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ពេជ្រ រស្មី អ៊ីមផត អិចផត** ១៦៧៩

១០-០១-២០០៦ -លិខិតលេខ ១២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេ ធី ធី ខមភេនី** ១៦៨១

១០-០១-២០០៦ -លិខិតលេខ ១២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ដាប់ប៊ែលយូ ប៊ី ឌី (ខេមបូឌា)** ១៦៨៣

១០-០១-២០០៦ -លិខិតលេខ ១២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **និត រ៉ាទី អ៊ីមផត អិចផត & គ្រេនស្ព័ត** ១៦៨៥

១០-០១-២០០៦ -លិខិតលេខ ១៣៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហេង ឌីភា អ៊ីមផត អិចផត** ១៦៨៧

១០-០១-២០០៦ -លិខិតលេខ១៣៤ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សុវណ្ណតារារិទ្ធ អ៊ីមផត អិចផត** ១៦៨៩

១០-០១-២០០៦ -លិខិតលេខ ១៣៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សែន ជ័យ អ៊ីមផត អិចផត** ១៦៩១

១១-០១-២០០៦ -លិខិតលេខ ១៤៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធីម អូឡៀន ឌីវេឡុបមេន** ១៦៩៣

០១-០២-២០០៦ -លិខិតលេខ ៣៩៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេក អ៊ីមផត អិចផត ខូ អិលធីឌី** ១៦៩៥

០២-០២-២០០៦ -លិខិតលេខ ៣៩៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉េង ផេង** ១៦៩៧

០២-០២-២០០៦ -លិខិតលេខ ៣៩៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យូ ឃៃរ ត្រេឌីង** ១៦៩៩

០៧-០២-២០០៦ -លិខិតលេខ ៤២២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធី.តី.ខេ ខេមបូ គ្រុប** ១៧០១

នស/រកត/០៣០៦/១៧៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី៤ នីតិកាលទី៣នៃរដ្ឋសភា នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតទុកចិត្តទៅលើការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

| | |
|---|---|
| -ឯកឧត្តម **ស ខេង** | បច្ចុប្បន្នជាឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ |
| -ឯកឧត្តម **ទៀ បាញ់** | បច្ចុប្បន្នជាឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ |
| -ឯកឧត្តម **ញឹក ប៊ុនឆៃ** | បច្ចុប្បន្នជាឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាឧបនាយករដ្ឋមន្ត្រី ។ |

**មាត្រា២ :** ត្រូវបានបញ្ចប់តំណែង សម្តេច **នរោត្តម សិរីវុឌ្ឍ** ពីឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៥ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤-០៦០៣.១២៨

លេខៈ ១២៧. ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៣ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឆារី តាន់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...២៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បរិវេណដីនៅក្រុងព្រះសីហនុ សម្រាប់ការអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិកងកេង និងហេដ្ឋារចនាសម្ព័ន្ធចំណុះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- តាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ពង្រីកហេដ្ឋារចនាសម្ព័ន្ធដែលមានរួចហើយ ដើម្បីកសាងជាអាកាសយានដ្ឋានអន្តរជាតិ លំដាប់ថ្នាក់ 4E ស្របតាមស្តង់ដារអន្តរជាតិ ដែលអាចទទួលបានអាកាសយានគ្រប់ប្រភេទ ទាំងអាកាសយានដឹកអ្នកដំណើរ និង

អាកាសយានដឹកទំនិញ ដើម្បីអភិវឌ្ឍន៍ និងបង្កើនសកម្មភាពទេសចរណ៍ ឧស្សាហកម្ម ពាណិជ្ជកម្ម ជាពិសេស ឧស្សាហកម្ម ប្រេងឥន្ធនៈ និងឧស្ម័ន នាអនាគត នៅតំបន់ក្រុងព្រះសីហនុដែលជាផលប្រយោជន៍សាធារណៈរបស់ជាតិ ។

**មាត្រា ២.-**

ធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ភ្ជាប់ជាឧបសម្ព័ន្ធ(ឧបសម្ព័ន្ធ ទី១) ដែលមានផ្ទៃក្រឡាសរុប ៦៨២ ហិកតា ជាប្រភេទដីមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ដែលមានទីតាំងស្ថិតនៅសង្កាត់រាម ខ័ណ្ឌព្រៃនុប ក្រុងព្រះសីហនុ ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥. ១៦. ១៧. នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ដើម្បីសម្រេចនូវគម្រោងនេះ និងមាននិយាមការ ដូចខាងក្រោម ÷

| | | | | | |
|---|---|---|---|---|---|
| (01) | 349698.2 E | 1171948.4 N | (21) | 351660.7 E | 1170416.8 N |
| (02) | 348926.5 E | 1170661.6 N | (22) | 351578.2 E | 1170481.3 N |
| (03) | 350128.5 E | 1169915.1 N | (23) | 350770.3 E | 1171111.2 N |
| (04) | 350352.0 E | 1169776.3 N | (24) | 351141.5 E | 1170714.3 N |
| (05) | 349885.5 E | 1168906.1 N | (25) | 350171.4 E | 1168854.6 N |
| (06) | 349419.0 E | 1168035.8 N | (26) | 349744.8 E | 1168058.7 N |
| (07) | 349033.9 E | 1167317.3 N | (27) | 350210.9 E | 1167808.8 N |
| (08) | 349686.5 E | 1166967.5 N | (28) | 350653.2 E | 1168613.8 N |
| (09) | 349926.7 E | 1167338.8 N | (29) | 349012.8 E | 1166988.1 N |
| (10) | 350194.2 E | 1167620.1 N | (30) | 349154.6 E | 1167252.5 N |
| (11) | 350337.4 E | 1167754.0 N | (31) | 349194.4 E | 1166890.7 N |
| (12) | 350547.9 E | 1167950.7 N | (32) | 349336.2 E | 1167155.2 N |
| (13) | 350747.8 E | 1168141.9 N | (33) | 348765.0 E | 1166815.3 N |
| (14) | 350906.3 E | 1168374.1 E | (34) | 348920.6 E | 1166308.2 N |
| (15) | 350986.3 E | 1168601.5 N | (35) | 349543.5 E | 1166307.9 N |
| (16) | 351044.7 E | 1169020.7 N | (36) | 349552.3 E | 1166716.9 N |
| (17) | 351162.0 E | 1169404.3 N | (37) | 351148.1 E | 1170971.3 N |
| (18) | 351288.8 E | 1169662.9 N | (38) | 351332.9 E | 1171316.1 N |
| (19) | 351351.9 E | 1169784.0 N | (39) | 351514.4 E | 1171218.8 N |
| (20) | 351634.6 E | 1170326.2 N | (40) | 351312.6 E | 1170842.2 N |

**មាត្រា ៣.-**

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ឬការផ្ទេរកម្មសិទ្ធិ ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់នៃអចលនវត្ថុទាំងឡាយតាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលឋិតក្នុងបរិវេណដីបង្ហាញដូចបាន ពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតអោយសាងសង់សំណង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការ ផ្ទេរកម្មសិទ្ធិជាផលប្រយោជន៍របស់ជាតិ និងការបង្កបង្កើនផលកសិកម្មដែលបានទទួលការអនុញ្ញាតពីគណៈកម្មការ ចំពោះកិច្ច ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងទទួលទណ្ឌកម្ម ដែលមានចែង នៅមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ។

**មាត្រា ៤.-**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃឡដី ក្នុងបរិវេណដែលនឹងត្រូវផ្ទេរកម្មសិទ្ធិ ឬភោគៈមកប្រគល់អោយរដ្ឋ នឹងទទួល បាននូវការទូទាត់សំណង ក្រោមកិច្ចការអង្កេត និងការឯកភាពលើសំណើសំណង ស្នើឡើងដោយគណៈកម្មការចំពោះ កិច្ចមួយ ដែលជាសេនាធិការមានភារកិច្ចក្នុងការសម្របសម្រួល និងដោះស្រាយនូវរាល់បញ្ហាខាងលើនេះ ហើយ

គណៈកម្មការនេះ នឹងតែងតាំងដោយប្រកាស របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៥.-**

ជាមួយគ្នានេះដែរ ប្លង់ស្តីពីសេវាភាពសម្រាប់ការហោះហើរនៃអាកាសយាន នឹងត្រូវបញ្ចូលក្នុងរាល់ឯកសារនគរូនីយកម្មនានា ដោយគោរពតាមលក្ខខ័ណ្ឌបច្ចេកទេស នៃ ការហោះហើរ ដូចមានចែងក្នុងឧបសម្ព័ន្ធ ទី២ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ព្រមទាំងអភិបាលក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ តាមភារកិច្ចរៀង១ខ្លួន ។

**មាត្រា ៧.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៦
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយការងារ
៙
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនសមាជិក សមាជិកា នៃសមាគមស្ថាប័នវិស្វកម្មកម្ពុជា និងអង្គការវិស្វកម្ម អន្តរជាតិ ចំនួន ២៥រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **លឹម** | **សុថាវ** | អគ្គហេរញ្ញិករងសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ២-លោក | **ម៉ក់** | **ការុណាដា** | អគ្គលេខាធិការរងសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៣-លោក | **ពេញ** | **សារះឃឿន** | អគ្គលេខាធិការរងសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៤-លោក | **ថាច់** | **សុវ៉ាល់សាយ** | លេខាធិការក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៥-លោក | **សរ** | **ឈុនលឹម** | ប្រធានរដ្ឋបាលនៃ លេខាធិការដ្ឋានសមាគមស្ថាប័ន |
| ៦-លោក | **អ៊ិត** | **ទឿន** | អនុប្រធានផ្នែកជំនាញឯកទេសស្ថាបត្យកម្ម នៃ ស.វ.ក |
| ៧-លោក | **ឃួន** | **ម៉ុណ្ណា** | អនុប្រធានផ្នែកជំនាញឯកទេសស្ថាបត្យកម្ម នៃ ស.វ.ក |
| ៨-លោក | **ជា** | **ស៊ីនហ៊ើល** | ប្រធានផ្នែកជំនាញឯកទេសបច្ចេកទេសអគ្គីសនី នៃ ស.វ.ក |
| ៩-លោក | **ចាំល់** | **ដែស** | ប្រធានផ្នែកជំនាញឯកទេសព័ត៌មានវិទ្យា នៃ ស.វ.ក |
| ១០-លោក | **កែវ** | **លាប** | ប្រធានផ្នែកជំនាញឯកទេសស្ពានថ្នល់ នៃ ស.វ.ក |
| ១១-លោក | **ចាន់** | **សុខេន** | ប្រធានគណៈកម្មាធិការវិស្វកម្ម ខេត្តកណ្ដាល នៃ ស.វ.ក |
| ១២-លោក | **សូ** | **សុខ** | ប្រធានគណៈកម្មាធិការវិស្វកម្ម ក្រុងព្រះសីហនុ នៃ ស.វ.ក |

១៣-លោកបណ្ឌិត **ម៉ឺន ណារិទ្ធ** ប្រធានផ្នែកជំនាញឯកទេស ថាមពលកកើតវិញ នៃ ស.វ.ក

១៤-លោកបណ្ឌិត **អ៊ឹម រម្យណី** អនុប្រធានផ្នែកជំនាញឯកទេស ថាមពលកកើតវិញ នៃ ស.វ.ក

១៥-បណ្ឌិត **លាង ឆាលី** អគ្គលេខាធិការរងសមាគមស្ថាប័នវិស្វកម្មកម្ពុជា

**ខ_មេជាយគ្រាក់ការងារ :**

១-លោក **ម៉ែន ខេមម៉ារ៉ា** អនុប្រធានផ្នែកជំនាញឯកទេសដឹកជញ្ជូន នៃ ស.វ.ក

២-លោក **សេង ស៊ីនហួរ** អនុប្រធានផ្នែកជំនាញឯកទេសបច្ចេកទេសអគ្គិសនីនៃ ស.វ.ក

៣-លោក **ស៊ុំ ស៊ីសុខាលី** អនុប្រធានផ្នែកជំនាញឯកទេសវិភូគព្ភសាស្ត្រ នៃ ស.វ.ក

៤-លោក **សុខ មុនីរតនា** អនុប្រធានផ្នែកជំនាញឯកទេសសំណង់ធារាសាស្ត្រនៃ ស.វ.ក

៥-លោក **មាស សាគុណ** ជំនួយការប្រធានសមាគមស្ថាប័នវិស្វកម្មកម្ពុជា

៦-លោក **ញ៉ៀម មឿន** អនុប្រធានផ្នែកជំនាញឯកទេសសំណង់ស៊ីវិលនៃ ស.វ.ក

៧-លោក **ហែម សុវិញ្ញូ** អនុប្រធានផ្នែកជំនាញឯកទេសសំណង់ស៊ីវិលនៃ ស.វ.ក

៨-លោក **ឈឹម សឿន** ប្រធានគណៈកម្មាធិការវិស្វកម្ម ខេត្តកំពត នៃ ស.វ.ក

៩-លោក **អំ ម៉ុនលី** អនុប្រធានផ្នែកជំនាញឯកទេសសំណង់ស៊ីវិល អាគារនៃ ស.វ.ក

១០-លោក **ជ្រា រ៉ាដា** អនុប្រធានផ្នែកជំនាញឯកទេសទីប្រឹក្សាបច្ចេកទេសនៃ ស.វ.ក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៣ ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសមាជិក សមាជិកា នៃសមាគមស្ថាប័នវិស្វកម្មកម្ពុជា ចំនួន ១៤រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយ នាមខាងក្រោមនេះ :-

**ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **ហូ** | **ណួន** | អនុប្រធានក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ២-ឯកឧត្តម | **ត្រាំ** | **អ៊ីវតិក** | អនុប្រធានក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៣-ឯកឧត្តម | **ជ័យ** | **ចាប** | អនុប្រធានក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៤-ឯកឧត្តម | **តិច** | **សំណាង** | ជំនួយការ ឯកឧត្តម សុខ អាន ទទួលបន្ទុកការងារវិស្វកម្ម |
| ៥-លោក | **មាស** | **សុខុម** | ប្រធានសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៦-លោក | **ប្រាក់** | **មិន** | អនុប្រធានសមាគមស្ថាប័នវិស្វកម្មកម្ពុជា |

**ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

| | | | |
|---|---|---|---|
| ១-លោក | **ចំន្ទ** | **តារារិទ្ធ** | អនុប្រធានសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ២-ឯកឧត្តម | **ម៉ែន** | **ដែន** | អនុប្រធានសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៣-លោក | **សុទ្ធ** | **សុបញ្ញា** | អគ្គលេខាធិការសមាគមស្ថាប័នវិស្វកម្មកម្ពុជា |
| ៤-លោក | **កោ** | **ជុន** | អគ្គហេរញ្ញិកសមាគមស្ថាប័នវិស្វកម្មកម្ពុជា |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

១-ឯកឧត្តម **សួស គង់** សមាជិកក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា

២-ឯកឧត្តម **លូ គីមឈុន់** សមាជិកក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា

៣-ឧកញ៉ា **ស៊ិន សុខណា** សមាជិកក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា

៤-ឧកញ៉ា **ហាន់ ឃាង** សមាជិកក្រុមប្រឹក្សាភិបាលសមាគមស្ថាប័នវិស្វកម្មកម្ពុជា

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...១៧៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធផលផ្សេងៗ ដូចជាឧបដ្ឋានសាលា ខ្លោងទ្វារ និងជងទង់ នៅវត្តពោធិ៍ដុះ ឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

១-លោក **ជា គឹមឡុង** នៅក្រុងភ្នំពេញ ថវិកា ចំនួន ១៦.១៦៨ ដុល្លារ
២-លោក **ពេជ ឆែម** នៅក្រុងភ្នំពេញ ថវិកា ចំនួន ១៤.៧១២ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៦
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ..១៣៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា

≈≈≈❋≈≈≈

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- អនុក្រឹត្យលេខ ៦៦ អនក្រ. បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១ :** តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (**វពជក**) ដែលមានរាយនាម ដូចខាងក្រោម :

១- ឯកឧត្តម **ពេជ សោភ័ន** តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាន

| | | | |
|---|---|---|---|
| ២- ឯកឧត្តម | **សយ ស៊ីផុន** | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣- ឯកឧត្តម | **សូស យ៉ារ៉ា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម | **លី សុមុនី** | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៥- ឯកឧត្តម | **អ៊ុក ស៊ីផាន** | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៦- ឯកឧត្តម | **ប៊ុន ភារិន** | នាយក នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | សមាជិកស្វ័យប្រវត្តិ |
| ៧- លោកឧកញ៉ា | **ឡាយ ប៊ុនប៉ា** | តំណាងសហគ្រិនឯកជន | សមាជិក |
| ៨- លោក | **គីម ទូច** | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩- លោក | **លី សែ** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- លោក | **ណាង សុធី** | តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១១- លោក | **នួន សារួន** | តំណាងបុគ្គលិកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | សមាជិកស្វ័យប្រវត្តិ |
| ១២- លោក | Lee Nahm Sik | តំណាងសកលវិទ្យាល័យ **ជុន ជូ** នៃសាធារណរដ្ឋកូរ៉េ | សមាជិក |

**មាត្រា២ :** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង-ស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានពហុបច្ចេកទេសកម្ពុជា និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ១៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រ…ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចលោក **ម៉ម ម៉ុននាង** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ពីអភិបាលរងទី១ ក្រុងភ្នំពេញ ឱ្យទៅបំរើការងារនៅទីស្តីការក្រសួងមហាផៃ ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៦*

**ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៨ សសរ

## សេចក្តីសំរេច
## ស្តីពីការផ្ទេរសិទ្ធិការចារបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋកូរ៉េ ចាប់ពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០០៦ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ២
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០៩ សសរ**

# សេចក្តីសម្រេច
# ស្តីអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ច
# របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ដែលទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ។

**ប្រការ ២:** ចំពោះនាយករដ្ឋមន្ត្រី: **សម្តេច ហ៊ុន សែន:** នាយករដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំរួម ការងាររបស់គណៈរដ្ឋមន្ត្រី ចាត់ចែងបញ្ជារាស់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ និងទទួលផ្ទាល់លើការងារគ្រប់គ្រងគ្រោះមហន្តរាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៣:** ចំពោះឧបនាយករដ្ឋមន្ត្រី :

**១-ឯកឧត្តម ស ខេង** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃជានាយករដ្ឋមន្ត្រីស្តីទី ពេលអវត្តមាននាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើកិច្ចការសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជួញដូរមនុស្ស ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភេរវកម្ម ដឹកនាំកិច្ចការវិមជ្ឈការ និងសហវិមជ្ឈការ គាំទ្រ កម្មវិធីសីលា ការកែទម្រង់ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួង

ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងផែនការ ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។

២_**ឯកឧត្តម សុខ អាន** : ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលកិច្ចការ សំរាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារតាមដានសម្របសម្រួល និងដឹកនាំកិច្ចការកែទំរង់រដ្ឋ ដំណើរការតុលាការ កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ការងារបំផ្លាញមីន និងជួយជនពិការដោយសារមីន និងពត៌មានវិទ្យា។ ជួយនាយករដ្ឋមន្ត្រីក្នុងការរៀបចំចម្លើយតបនឹងសំនួររបស់សមាជិករដ្ឋសភា តាមនីតិវិធីដូចមានចែងក្នុងមាត្រាទី ៩៦ នៃរដ្ឋធម្មនុញ្ញ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងពត៌មាន ក្រសួងអប់រំយុវជននិងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងដឹកនាំអាជ្ញាធរជាតិប្រេងកាត និងដោះស្រាយជម្លោះដីធ្លី ។

៣_**ឯកឧត្តម លី ឡាយស្រេង** : ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី និងក្រសួងធម្មការ និងកិច្ចការសាសនា ។

៤_**ឯកឧត្តម ទៀ បាញ់** : ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើការងារការពារជាតិទទួលសិទ្ធិពីនាយករដ្ឋមន្ត្រីក្នុងការងារគ្រប់គ្រង និងបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៥_**ឯកឧត្តម ហោ ណាំហុង** : ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីលើការងារ ការបរទេស និងសហប្រតិបត្តិការអន្តរជាតិទូទៅ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រីក្នុងការងារសម្របសម្រួល គ្រប់គ្រងក្រសួងពាណិជ្ជកម្ម និងគណៈកម្មាធិការជាតិទន្លេមេគង្គ ។

៦_**ឯកឧត្តម ញឹក ប៊ុនឆៃ**: ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រីក្នុងការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម និងជួយឯកឧត្តម ទៀ បាញ់ ក្នុងការងារគ្រប់គ្រងនិងបញ្ជាកងរាជអាវុធ_ហត្ថ លើផ្ទៃប្រទេស ។ ទន្ទឹមនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ ជួយនាយករដ្ឋមន្ត្រីលើការងារសម្របសម្រួលគ្រប់គ្រងក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសុខាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ញឹក ប៊ុនឆៃ ដឹកនាំគណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍន៍ គណៈកម្មការត្រួតពិនិត្យដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង ចំណុះអោយអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងកិច្ចការមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី ។

**ប្រការ ៤**: នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារតាមការកោះអញ្ជើញពីនាយករដ្ឋមន្ត្រី ឬពីនាយករដ្ឋមន្ត្រីស្តីទី ។

**ប្រការ ៥:** ឧបនាយករដ្ឋមន្ត្រីទទួលអនុវត្តការងារ ឬបេសកកម្មផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ស្របតាមមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦:** ឧបនាយករដ្ឋមន្ត្រី ១ រូប១ មានទីប្រឹក្សា ៤ រូប ក្នុងនោះ ២ រូប មានឋានៈស្មើរដ្ឋលេខាធិការ ២ រូប មានឋានៈស្មើអនុរដ្ឋលេខាធិការ និងជំនួយការ ៣ រូប ក្នុងនោះ ១ រូប មានឋានៈស្មើអគ្គនាយក ១ រូប មានឋានៈស្មើអគ្គនាយករង និង ១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ ៧:** ចំពោះទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស :

១_ឯកឧត្តម ហុង ស៊ុនហួត ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរអេដស៍

២_ឯកឧត្តម ឃី តាំងលីម ទេសរដ្ឋមន្ត្រីទទួលបន្ទុកជារដ្ឋមន្ត្រីអមមហាអនុតំបន់ទន្លេមេគង្គ

៣_ឯកឧត្តម វេង សិរីវុឌ្ឍ ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងជាប្រធានក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ

៤_ឯកឧត្តម ញឹម វណ្ណដា ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

៥_ឯកឧត្តម តាវ សេងហួរ ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

៦_ឯកឧត្តម ស៊ី កុសល ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី ២ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

**ប្រការ ៨:** ទេសរដ្ឋមន្ត្រីទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀតដែលនាយករដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ ៩:** ទេសរដ្ឋមន្ត្រីដែលទទួលបន្ទុកបេសកកម្មពិសេសមានជំនួយការ ២ រូប ក្នុងនោះ ១ រូប មានឋានៈស្មើអគ្គនាយករង និង ១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ១០:** នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង_ស្ថាប័ន ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

_*ក្រសួងព្រះបរមរាជវាំង*

_*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

_*អគ្គលេខាធិការដ្ឋានរដ្ឋសភា*

_*ទីស្តីការគណៈរដ្ឋមន្ត្រី*

_*អគ្គលេខាធិការរាជរដ្ឋាភិបាល*

_*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

_*ដូចប្រការ ២_៣_៧_១០*

_*ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...០២...សរ.ន

# សារាចរ

# ស្តីពី

# ការអនុញ្ញាតឱ្យប្រើប្រាស់រថយន្តចង្កូតស្តាំ ដែលមានស្រាប់នៅក្នុងប្រទេស

-------

ប៉ុន្មានឆ្នាំចុងក្រោយនេះ បន្ទាប់ពីការខិតខំប្រឹងប្រែងស្តាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅទូទាំងប្រទេសរួចមក រាជរដ្ឋាភិបាលបានសង្កេតឃើញថា ចំនួនយានយន្តគ្រប់ប្រភេទបានកើនឡើងឥតឈប់ឈរ ដែលបង្កឱ្យមានការកកស្ទះ ការបាត់សណ្តាប់ធ្នាប់សាធារណៈ និងគ្រោះថ្នាក់ចរាចរជាញឹកញាប់នៅតាមដងផ្លូវ។ គ្រោះថ្នាក់ចរាចរនេះ មួយផ្នែកបង្កឡើងដោយអ្នកបើកបររថយន្តចង្កូតស្តាំដែលគ្មានផ្លាកលេខ ពាក់ផ្លាកលេខក្លែងក្លាយ និងគ្មានការបង់ពន្ធនាំចូល ហើយបើកបរគេចពីសមត្ថកិច្ចត្រួតពិនិត្យតាមដងផ្លូវ ដែលបានបង្កឡើងនូវបទឧក្រិដ្ឋ បទល្មើសចរាចរ និងធ្វើឱ្យបាត់បង់ចំណូលថវិការដ្ឋ ។

ដើម្បីកែលំអនូវបាតុភាពអសកម្មខាងលើ បង្កើនការគ្រប់គ្រងយានយន្តគ្រប់ប្រភេទឱ្យបានកាន់តែល្អប្រសើរ និងការបង្កើនចំណូលថវិការដ្ឋ រាជរដ្ឋាភិបាលធ្វើការណែនាំដូចតទៅ :

១- អនុញ្ញាតឱ្យរថយន្តចង្កូតស្តាំគ្រប់ប្រភេទ ដែលបាននាំចូលកន្លងមកទាំងអស់ មានសិទ្ធិធ្វើចរាចរដោយស្របច្បាប់លើផ្លូវសាធារណៈ ដោយត្រូវបំពេញកាតព្វកិច្ចបង់ពន្ធ និងធ្វើផ្លាកលេខឱ្យបានត្រឹមត្រូវចាប់ពីពេលនេះតទៅ។

២- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវរៀបចំជាបន្ទាន់នូវប្រកាសរួមអន្តរក្រសួង ដើម្បីណែនាំដល់ទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ ឱ្យមានវិធានការម៉ឺងម៉ាត់ដល់ម្ចាស់រថយន្តចង្កូតស្តាំទាំងអស់ ឱ្យបំពេញកាតព្វកិច្ចបង់ពន្ធឱ្យបានត្រឹមត្រូវ និងសមស្របតាមប្រភេទ និងគុណភាពរថយន្ត និងធ្វើការណែនាំដល់អគ្គនាយកដ្ឋានដឹកជញ្ជូនឱ្យផ្តល់ប័ណ្ណសំគាល់ និងផ្លាកលេខរថយន្តចង្កូតស្តាំ ដែលបានបំពេញកាតព្វកិច្ចបង់ពន្ធរួចហើយឱ្យបានឆាប់

របស់ រួចបញ្ជូនបញ្ជីវត្ថុទាំងនោះ ទៅអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃដើម្បីគ្រប់គ្រងបន្ត។

៣- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ត្រូវធ្វើការណែនាំជាបន្ទាន់ដល់មន្ត្រីមានសមត្ថកិច្ច ដែលបំពេញការងារនៅតាមច្រកទ្វារព្រំដែនទាំងអស់ ត្រូវទប់ស្កាត់ និងបញ្ឈប់មិនឱ្យមានការនាំចូលជាដាច់ខាតនូវវត្ថុចង្កូតស្ពាំគ្រប់ប្រភេទជាបន្តទៀត ចាប់ពីពេលនេះតទៅ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងអាជ្ញាធរដែនដីពាក់ព័ន្ធទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្ត ឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៣៦ ឧរក ក្រ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ ១២ ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៥០១៦/០៥ គ.វ.ក ចុះថ្ងៃទី ១៤.១២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌឺរី ខូអិលធីឌី ចុះថ្ងៃទី ១១.១១.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌឺរី ខូអិលធីឌី ( YU JIE COMPUTER EMBROIDERY CO., LTD.) តំណាងដោយលោក LIU, CHIN-MING សញ្ជាតិចិន ( តៃវ៉ាន់) អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 131699366 ចុះថ្ងៃទី១៦.០៥.២០០១ បង្កើតសាខារោងចក្រ "ចាក់សម្លៀកបំពាក់" ដែលមានឈ្មោះថា អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌឺរី ខូអិលធីឌី សាខាទី១ (YU JIE COMPUTER EMBROIDERY CO., LTD. No 1)" មានទីតាំងស្ថិតនៅ ភូមិត្រពាំងទា សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ“ចាក់សម្លៀកបំពាក់”ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌី ខូអិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

អ៊ិត-ប្រាំង

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

“ ដើម្បីជូនជ្រាប ”

- ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៣៧/[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ មីនា ឆ្នាំ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៤៣៥/០០ ក.វ.ក ចុះថ្ងៃទី ២៣.០៥.២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌឺរី ខូ អិលធីឌី ចុះថ្ងៃទី ២៥.០៣.២០០៥

## សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌឺរី ខូ អិលធីឌី (YU JIE COMPUTER EMBROIDERY CO., LTD.) តំណាងដោយលោក LIU, CHIN-MING សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 131699366 ចុះថ្ងៃទី១៦.០៥.២០០១ បង្កើតរោងចក្រ "ប៉ាក់សម្លៀកបំពាក់ " ដែលមានឈ្មោះថា អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌឺរី ខូ អិលធីឌី (YU JIE COMPUTER EMBROIDERY CO., LTD. )" មានទីតាំងស្ថិតនៅ ផ្លូវលេខ១៥ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ"ចាក់សម្លៀកបំពាក់"ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អ៊ីជា កុំព្យូទ័រ អ៊ឹមប្រូឌឺរី ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

អ៊ិត-ប្រាំង

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៤៥ ឧរថ. ករ. - ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី២៣ខែ មីនា ឆ្នាំ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៧៨៦/០៦ គ.វ.ក ចុះថ្ងៃទី ២៨.០២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សិរីធន អ៊ិនដាសស្រ្ទៀល ហ្គាមេន ចុះថ្ងៃទី១៦.០២.២០០៦

## សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន សិរីធន អ៊ិនដាសស្រ្ទៀល ហ្គាមេន (SEREY THUN INDUSTRIAL GARMENT CO., LTD.) តំណាងដោយលោក ហាស់ ម៉េងឡុង សញ្ជាតិខ្មែរ អាយុ២៦ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 010497152 ចុះថ្ងៃទី១៥.០៦.២០០៥ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "សិរីធន អ៊ិនដាសស្រ្ទៀល ហ្គាមេន **(SEREY THUN INDUSTRIAL GARMENT)**" មានទីតាំងស្ថិតនៅ ភូមិព្រែកទាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន សិរីធន អ៊ិនដាសស្ទ្រៀល ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ជ. រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

អ៊ិត ប្រាំង

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

  " ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
N° ៣៤៦ ឧរថ.កន.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៣ខែ មីនា ឆ្នាំ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៧៦៨/០៦ គ.វ.ក ចុះថ្ងៃទី២៤.០២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញប្រកាសលេខ ៣៧៧ ជក.ប្រក ចុះថ្ងៃទី១០.០៦.១៩៩៦ របស់ក្រុមហ៊ុន MIGHTI SPECTRA KNITTING FACTORY CO., LTD.
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ៊ីង អ៊ី នីតធីង ហ្វេកធើរី កូ អិលធីឌី ចុះថ្ងៃទី២៥.០១.២០០៦

## សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ីង អ៊ី នីតធីង ហ្វេកធើរី កូ អិលធីឌី (HENG YU KNITTING FACTORY CO., LTD.) តំណាងដោយ លោក LAM BUN សញ្ជាតិចិន (ហុងកុង) អាយុ៣៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H90091383 ចុះថ្ងៃទី១២.០៩.២០០០ បង្កើតរោងចក្រ"ចាក់សម្លៀកបំពាក់" ដែលមានឈ្មោះថា"ហ៊ីង អ៊ី នីតធីង ហ្វេកធើរី កូ អិលធីឌី (HENG YU KNITTING FACTORY CO., LTD.)" មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៦ អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "ចាក់សម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: ប្រកាសលេខ៣៧៧ ផក.ប្រក ចុះថ្ងៃទី១០.០៦.១៩៩៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការ បង្កើតរោងចក្រកាត់ដេរ និង ចាក់សម្លៀកបំពាក់ របស់ក្រុមហ៊ុន (MIGHTI SPECTRA KNITTING FACTORY CO., LTD) ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១០: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ហ៊ីង អ៊ី នីតធីង ហ្វេកធើរី កូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១១: ប្រកាសនេះមានអនុភាពតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក
ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ១០ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ :......១៦៦.............ប្រក.កសក.ប

## ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៤០អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងតាមបណ្តា ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

# សម្រេច

**ប្រការ១ :** នាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាអង្គភាពមួយចំណុះឱ្យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចដូចខាងក្រោម :

១. រៀបចំផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ ដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សំរេច ។

២. ពិនិត្យឡើងវិញលើមុខងារ សកម្មភាពកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសម ស្របរបស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតំរង់ទិស ការចាត់ចែងនិង ការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និង នីតិវិធីនៃការគ្រប់គ្រងឱ្យបាន ត្រឹមត្រូវតាមគោលដៅរបស់អង្គភាព ។

៣. កំណត់នូវភាពសមស្រប គ្រប់គ្រាន់និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែកគណនេយ្យរដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព ។

៤. ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មាន ហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណវាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ ។

៥. ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ បទបញ្ជាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍ ។ ក្នុងករណីអង្គភាព អនុវត្តពុំបានសមស្របដូចបានរៀបរាប់ខាងលើ ចាំបាច់សំណូមពរឱ្យមានការផ្លាស់ប្តូរ និងកែលំអ ។

៦. ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំ ការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឱ្យបានត្រឹមត្រូវ ។

៧. វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធិភាពលើការប្រើប្រាស់ធនធាន និងកំណត់ការកែលំអលើការអនុវត្ត កិច្ចប្រតិបត្តិការ និងផ្តល់អនុសាសន៍ ។

៨. ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធី និងគំរោងចំណាយមូលធន លើលទ្ធផលការងារវិជ្ជមាន ឬ អវិជ្ជមានតាមគោលបំណង គោលដៅដែលបានដាក់ចេញ និងតាមផែនការដែលបានកំណត់ ។

៩. ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗដើម្បីធានាឱ្យ :

ក- តំរូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាស់លាស់ ។

ខ- ការត្រួតពិនិត្យផ្ទៃក្នុងសមស្របត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ។

គ- ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រត្រូវបានប្រព្រឹត្តទៅក្នុងជំហានសមស្រប ។

ឃ-ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ ។

១០. ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យ សំខាន់ៗ ក្រោយពេលតម្លើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះ ឆ្លើយតបតាមគោលបំណង និងគោលដៅ ដែលបានគ្រោង ទុក ហើយទទួលបានលទ្ធផលមានសុវត្ថិភាព និងប្រសិទ្ធិភាពខ្ពស់ ។

១១. ពិនិត្យឡើងវិញលើនីតិវិធី និង ការអនុវត្តដើម្បីធានាថា វិធានការត្រូវបានដាក់ចេញក្នុងគោលបំណង ការពារ ការកេងបន្លំ ។ ប្រសិនបើមានការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបាន

ទាន់ពេលវេលា ។

១២. ពិនិត្យឡើងវិញលើការអនុវត្ត តាមគោលការណែនាំ និងការគ្រប់គ្រង របស់រាជរដ្ឋាភិបាល ស្តីពី ឥរិយាបថ និងក្រមសីលធម៌ចំពោះមន្ត្រីរាជការ ។

១៣. សំរបសំរួលការងារសវនកម្មផ្ទៃក្នុង ជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់ គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា ។

១៤. ធ្វើរបាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយត្រូវផ្ញើរបាយការណ៍ និង សេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះ ទៅអាជ្ញាធរសវនកម្មជាតិស្តីពី :

ក- សកម្មភាពកែលំអតាមអនុសាសន៍សំខាន់ៗ របស់សវនកម្មផ្ទៃក្នុង

ខ- សកម្មភាពសវនកម្មត្រូវបានផ្តោតលើហានិភ័យ និង បង្កើតភាពសន្សំសំចៃប្រសិទ្ធិភាព និង ការផ្តល់ លទ្ធផលល្អក្នុងកិច្ចប្រតិបត្តិការ ។

គ- សវនកម្មផ្ទៃក្នុងត្រូវធ្វើការសំរបសំរួលការងារជាមួយ អាជ្ញាធរសវនកម្មជាតិ ដើម្បី ចៀសវាងការ ធ្វើសវនកម្មស្ទួនគ្នា ។ ក្នុងករណីមានភាពមិនច្បាស់លាស់អាជ្ញាធរសវនកម្មជាតិអាចធ្វើការត្រួត ពិនិត្យ និងធ្វើសវនកម្មសារឡើងវិញ ។

ឃ- ផែនការសវនកម្មផ្ទៃក្នុង ត្រូវមានភាពសមស្របច្បាស់លាស់ គ្រប់គ្រាន់ ។

ង- បញ្ហារារាំងលើព័ត៌មាន និងបញ្ជី ។

១៥. វាយតម្លៃផែនការ ឬសកម្មភាពកែលំអលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង។ ប្រសិនបើសកម្មភាព កែលំអនេះ មិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្ត ដើម្បីឱ្យសំរេចបានតាម សំណូមពរដែលអាចទទួលយកបាន ។

១៦. ផ្តល់លទ្ធភាពសមស្របគ្រប់គ្រាន់ក្នុងការតាមដានសកម្មភាពកែលំអលើអនុសាសន៍ ។

១៧. ប្រធានសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ ដោយផ្ទាល់ជូនថ្នាក់ដឹកនាំក្រសួង ។

១៨. ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវនកម្ម ផ្ញើជូនដល់អង្គភាពនីមួយៗក្រោមឱវាទក្រសួងដែល ទទួល បន្ទុកកែលំអតាមអនុសាសន៍ ។ សវនកម្មផ្ទៃក្នុងត្រូវបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅ ថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន ។

១៩. អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗ ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដឹកនាំដោយ ប្រធាន ១ រូប និង អមដោយអនុប្រធានមួយចំនួន ជាជំនួយការ ។

**ប្រការ២ :** នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានការិយាល័យចំណុះ ដូចខាង ក្រោម :-

**១- ការិយាល័យរដ្ឋបាល និង បុគ្គលិក**

**២- ការិយាល័យសវនកម្មទី ១**

២

**៣- ការិយាល័យសវនកម្មទី ២**

**៤- ក ិយាល័យសវនកម្មទី ៣**

**ប្រការ ៣ :** តួនាទីនិងភារកិច្ចរបស់ការិយាល័យរដ្ឋបាល និង បុគ្គលិក និង ការទទួលបន្ទុកធ្វើសវនកម្មរបស់ការិយាល័យសវនកម្មនីមួយៗ លើអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និង មន្ទីរកសិកម្មខេត្ត-ក្រុង មានដូចខាងក្រោម :

**១- ការិយាល័យរដ្ឋបាល និង បុគ្គលិក មានភារកិច្ច:**

- គ្រប់គ្រង ចរាចរឯកសាររដ្ឋបាល ឯកសារគតិយុត្តិ ឯកសារបច្ចេកទេស និង ឯកសាររៀនសូត្រ
- កសាងផែនការរយៈពេលខ្លី រយៈពេលមធ្យម និង រយៈពេលវែង របស់នាយកដ្ឋាន
- រៀបចំកម្មវិធី និងកាលវិភាគការងារជូនថ្នាក់ដឹកនាំនាយកដ្ឋាន និងទទួលបន្ទុកការងារពិធីការ
- បូកសរុបនិងធ្វើរបាយការណ៍នានា និងសរុបផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងស្ថិតិមន្ត្រីរាជការ និងរៀបចំឯកសារ តម្លើងឋានៈ បន្ថយឋានៈ សម្រួលភារកិច្ចមន្ត្រីរាជការ ផ្តល់គ្រឿងឥស្សរិយយស ការងារបៀវត្សនិងសង្គមកិច្ច និងការងារអភិវឌ្ឍន៍ធនធានមនុស្ស
- ចូលរួមសហការលើការធ្វើសវនកម្ម តាមបណ្តាអង្គភាពនានា
- ធានាប្រក្រតីភាពកិច្ចការរដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់ និងពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់នាយកដ្ឋាន
- លើកគំរោងចំណាយ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រងនិងដំណើការកិច្ចការគណនេយ្យ គ្រប់គ្រងបញ្ជីចលនវត្ថុ អចលនវត្ថុ សម្ភិធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់នាយកដ្ឋាន
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

**២- ការិយាល័យសវនកម្មទី១ ទទួលបន្ទុកធ្វើសវនកម្ម :**

**- នាយកដ្ឋាន និង អង្គភាពចំណុះ**

- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
- រដ្ឋបាលព្រៃឈើ
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- នាយកដ្ឋានគ្រឿងយន្តកសិកម្ម
- អង្គភាពដែលមានគំរោងចំណាយថវិកាបដិភាគ កម្ចី និង ជំនួយ

**- គ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ**

- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- ក្រុមហ៊ុនជលផល

- ចំការកៅស៊ូជប់
- ចំការកៅស៊ូបឹងកេត

- **មន្ទីរកសិកម្មខេត្ត-ក្រុង**
  - មន្ទីរកសិកម្មខេត្តកណ្តាល
  - មន្ទីរកសិកម្មខេត្តស្វាយរៀង
  - មន្ទីរកសិកម្មខេត្តព្រៃវែង
  - មន្ទីរកសិកម្មខេត្តកំពង់ចាម
  - មន្ទីរកសិកម្មខេត្តក្រចេះ
  - មន្ទីរកសិកម្មខេត្តរតនគិរី
  - មន្ទីរកសិកម្មខេត្តមណ្ឌលគិរី
  - មន្ទីរកសិកម្មខេត្តស្ទឹងត្រែង
  - ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

**៣- ការិយាល័យសវនកម្មទី២ ទទួលបន្ទុកធ្វើសវនកម្ម :**

- **នាយកដ្ឋាន និងអង្គភាពចំណុះ**
  - អគ្គាធិការដ្ឋាន
  - នាយកដ្ឋានផែនការ និង ស្ថិតិ
  - នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
  - នាយកដ្ឋានជលផល
  - នាយកដ្ឋានកសិ-ឧស្សាហកម្ម
  - មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម
- **គ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ**
  - វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
  - សាលាជាតិកសិកម្មកំពង់ចាម
  - ក្រុមហ៊ុនសំភារៈកសិកម្ម
  - ចំការកៅស៊ូចំការអណ្តូង
  - ចំការកៅស៊ូមេមត់
- **មន្ទីរកសិកម្មខេត្ត-ក្រុង**
  - មន្ទីរកសិកម្មរាជធានីភ្នំពេញ
  - មន្ទីរកសិកម្មខេត្តតាកែវ
  - មន្ទីរកសិកម្មក្រុងព្រះសីហនុ
  - មន្ទីរកសិកម្មខេត្តកំពត

៧

- មន្ទីរកសិកម្មក្រុងកែប
- មន្ទីរកសិកម្មខេត្តកោះកុង
- មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ
- មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

**៤- ការិយាល័យសវនកម្មទី៣ ទទួលបន្ទុកធ្វើសវនកម្ម :**

**- នាយកដ្ឋាន និងអង្គភាពចំណុះ**

- អគ្គនាយកដ្ឋាន ចំការកៅស៊ូ
- នាយកដ្ឋាន នីតិកម្មកសិកម្ម
- នាយកដ្ឋាន គណនេយ្យ - ហិរញ្ញវត្ថុ
- នាយកដ្ឋាន ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម
- នាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាល

**- គ្រឹះស្ថានសាធារណៈរដ្ឋបាល និង សហគ្រាសសាធារណៈ**

- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាលាជាតិកសិកម្មព្រែកលៀប
- ចំការកៅស៊ូស្នួល
- ចំការកៅស៊ូក្រែក
- ចំការកៅស៊ូពាមជាំង

**- មន្ទីរកសិកម្មខេត្ត-ក្រុង**

- មន្ទីរកសិកម្មខេត្តបាត់ដំបង
- មន្ទីរកសិកម្មខេត្តសៀមរាប
- មន្ទីរកសិកម្មខេត្តកំពង់ធំ
- មន្ទីរកសិកម្មខេត្តព្រះវិហារ
- មន្ទីរកសិកម្មខេត្តឧត្តមានជ័យ
- មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ
- មន្ទីរកសិកម្មក្រុងប៉ៃលិន
- មន្ទីរកសិកម្មខេត្តពោធិសាត់
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

**ប្រការ ៤ :** ការិយាល័យសវនកម្មនីមួយៗ មានភារកិច្ច ដូចខាងក្រោមនេះ :

- សហការរៀបចំផែនការសវនកម្មប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំនាយកដ្ឋានពិនិត្យ និង សម្រេច
- ធ្វើសវនកម្មលើមុខងារ រចនាសម្ព័ន្ធ ទស្សនទាន យុទ្ធសាស្ត្រ កម្មវិធី វិធានការ បទបញ្ញា

ក

មគោលនយោបាយ និងការចាត់តាំងការងាររបស់អង្គភាព ឱ្យស្របតាមនីតិវិធី បច្ចុប្បភាពនៃសមោកាស គោលការណ៍ណែនាំថ្នាក់ដឹកនាំ និងកម្មវត្ថុរបស់អង្គភាព

- ធ្វើសវនកម្មលើការអនុវត្តច្បាប់ បទបញ្ញានានា វិន័យថវិកាគណនេយ្យ-ហិរញ្ញវត្ថុ និងអភិបាលកិច្ចល្អនៅក្នុងប្រតិបត្តិការ ហិរញ្ញវត្ថុ ពិសេសការគៀងគរ និង គ្រប់គ្រងចំណូល ការចំណាយថវិកា ហិរញ្ញប្បទាន បំណុល និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ធ្វើសវនកម្មរាល់ពាក្យបណ្តឹងរបស់បណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រក្សារបាយការណ៍សវនកម្ម ឱ្យបានល្អសំរាប់មូលដ្ឋានតាមដាន ផ្ទៀងផ្ទាត់លើវឌ្ឍនភាព នៃការអនុវត្តអនុសាសន៍កែលំអ
- ផ្តល់សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ព្រមទាំងរបាយការណ៍ជូន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
- តាមដានជាប្រចាំនូវឯកសារគតិយុត្តិ និង សកម្មភាពកែទំរង់គណនេយ្យ និងហិរញ្ញវត្ថុសាធារណៈរបស់អង្គភាពនីមួយៗ
- ចូលរួមសហការជាមួយអង្គភាព និង ស្ថាប័នដែលពាក់ព័ន្ធ សំដៅកសាងមូលដ្ឋានព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ និងមានភាពសុក្រឹត
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ប្រការ៥ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានផែនការ និង ស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៸ៜ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ដូចមានចែងក្នុងប្រការ ៦

"ដើម្បីអនុវត្ត"

- មន្ទីរកសិកម្មគ្រប់ខេត្ត-ក្រុង

"ដើម្បីជ្រាប"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និង នេសាទ

ឧបសម្ព័ន្ធនៃប្រកាសលេខ ១១៦ ប្រក.កសក.ប ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦

## អង្គការលេខរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣✻៤

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ១៥៣ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## នីតិវិធីកំណត់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ បក ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញសេចក្តីសំរេចលេខ ២០សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយចំពោះជនពលី ពិការ និងលិខិតលេខ ៥១៥ សជណ អវ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩១ របស់រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ និងអនុក្រឹត្យលេខ ០២ អនក្រ បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែតម្រូវឡើងវិញមាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យ លេខ ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសារាចរអន្តរក្រសួងលេខ ០៤ សកអ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៤ របស់ក្រសួង សង្គមកិច្ច ការងារនិងអតីត

យុទ្ធជន ក្រសួងសុខាភិបាល ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ស្តីពីរបៀបបំពេញសំណុំលិខិត និង សំរេចទទួលស្គាល់ ជនពលី ពិការ

-បានឃើញសារាចរណែនាំ អន្តរក្រសួងលេខ ០២ សរណ អក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៥ របស់ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកាឆ្នាំ ១៩៩៦ ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ និងអនុក្រឹត្យលេខ ០២ អនក្រ បក ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៥ ស្តីពីការកែតម្រូវឡើងវិញ មាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យលេខ ៤៦ អនក្រ បក

-បានឃើញប្រកាសលេខ ៦៧៨ សអយ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០០៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីនីតិវិធីអនុវត្ត របបឧបត្ថម្ភគោលនយោបាយ ចំពោះជនពលី ជនមរណៈ ជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងគ្រួសារ ។

## សម្រេច

## ជំពូក១
## គោលការណ៍ទូទៅ

**ប្រការ១:** ប្រកាសនេះកំណត់ នូវបែបបទ និងនីតិវិធី នៃការផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូង ជូនជនពិការប្រភេទ ក ដូចមានចែងក្នុងវាក្យខ័ណ្ឌ ឃ ១៣ និង ក ១៤ ប្រការ ៧ នៃសេចក្តីសំរេចលេខ ២០ សសរ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយចំពោះ ជនពលី ពិការ និងលិខិតលេខ ៥១៥ សជណ អវ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៩១ របស់រដ្ឋមន្ត្រី ទទួលបន្ទុកខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី វាក្យខ័ណ្ឌ ក៤ មាត្រា៦ នៃអនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកាឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ និង វាក្យខ័ណ្ឌ ក៤ មាត្រា ៦ ថ្មី នៃអនុក្រឹត្យ លេខ ០២ អនក្រ បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែតម្រូវឡើងវិញ មាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃអនុ ក្រឹត្យលេខ ៤៦ អនក្រ បក ។

**ប្រការ២:** ជនពិការប្រភេទ ក ដែលត្រូវបានទទួលប្រាក់ឧបត្ថម្ភមួយលើកដំបូង ត្រូវមានលក្ខខ័ណ្ឌកំណត់តាមគោលការណ៍ ជាធរមាន ដូចខាងក្រោម :

១-ជនពិការ ដែលត្រូវទទួលរបបឧបត្ថម្ភ តាមការកំណត់ របស់សេចក្តីសំរេចលេខ ២០ សសរ ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មាន ៤ ប្រភេទ ដូចតទៅ :

ក-ជនពិការ ជាអតីតយោធិន

ខ-ជនពិការ ជាអតីតនគរបាលជាតិ

គ-ជនពិការ ជាអតីតមន្ត្រីរដ្ឋការ ឬមន្ត្រីរាជការស៊ីវិល ក្រុមខ័ណ្ឌមុខងារសាធារណៈ

ឃ-ជនពិការ ជាអតីតមន្ត្រីភូមិ ឃុំ កងសេនាជន ក្រៅក្របខ័ណ្ឌមុខងារសាធារណៈ និងប្រជាជន

២- ជនពិការ ដែលត្រូវទទួលរបបឧបត្ថម្ភ តាមការកំណត់របស់ អនុក្រឹត្យលេខ ៤៦ អនក្រ បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្គស្លាប់ បាត់ខ្លួន និងពិការ ដែលជនពិការទាំងនោះ ជាអតីតយោធិន នៃកងយោធពលខេមរភូមិន្ទ ។

៣-ជនពិការ ដែលត្រូវទទួលរបបឧបត្ថម្ភ តាមការកំណត់របស់ អនុក្រឹត្យលេខ ៣៤ អនក្រ បក ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ១៩៩៩ និង អនុក្រឹត្យលេខ ០២ អនក្រ បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកែតម្រូវឡើងវិញ មាត្រា ៣ មាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យលេខ ៤៦ អនក្រ បក ដែលជនពិការទាំងនោះ ជាអតីតយោធិន នៃកងយោធពលខេមរភូមិន្ទ។

**ប្រការ៣**: ការគិតប្រាក់ឧបត្ថម្ភមួយលើកដំបូង ជូនជនពិការ ត្រូវផ្អែកលើគោលការណ៍កំណត់ ដូចខាងក្រោម :

១-ជនពិការដែលស្ថិតក្នុងប្រភេទ ក ខ គ វាក្យខ័ណ្ឌ ១ នៃប្រការ ២ ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភជូន ដូចតទៅ :

-ថ្នាក់ទី១ ត្រូវបានទទួលចំនួន ៦ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ

-ថ្នាក់ទី២ ត្រូវបានទទួលចំនួន ៤ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ

-ថ្នាក់ទី៣ ត្រូវបានទទួលចំនួន ៣ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ

-ថ្នាក់ទី៤ ត្រូវបានទទួលចំនួន ២ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ ។

២-ជនពិការដែលស្ថិតក្នុងប្រភេទ ឃ វាក្យខ័ណ្ឌ ១ នៃប្រការ ២ ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភជូន ដូចតទៅ :

-ថ្នាក់ទី១ ត្រូវបានទទួលចំនួន ៦ ខែ នៃអតីតប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនប្រចាំខែ របស់យុទ្ធជនពលទោ

-ថ្នាក់ទី២ ត្រូវបានទទួលចំនួន ៤ ខែ នៃអតីតប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនប្រចាំខែ របស់យុទ្ធជនពលទោ

-ថ្នាក់ទី៣ ត្រូវបានទទួលចំនួន ៣ ខែ នៃអតីតប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនប្រចាំខែ របស់យុទ្ធជនពលទោ

-ថ្នាក់ទី៤ ត្រូវបានទទួលចំនួន ២ ខែ នៃអតីតប្រាក់បៀវត្សឋានន្តរសក្តិសរុបផ្ទាល់ខ្លួនប្រចាំខែ របស់យុទ្ធជនពលទោ ។

៣-ជនពិការដែលស្ថិតក្នុងវាក្យខ័ណ្ឌ ២ នៃប្រការ ២ ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភជូន ដូចតទៅ :

-ថ្នាក់ទី១ ត្រូវបានទទួលចំនួន ០៦ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ

-ថ្នាក់ទី២ ត្រូវបានទទួលចំនួន ០៥ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ

-ថ្នាក់ទី៣ ត្រូវបានទទួលចំនួន ០៤ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ

-ថ្នាក់ទី៤ ត្រូវបានទទួលចំនួន ០៣ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ

៤-ជនពិការដែលស្ថិតក្នុងវាក្យខ័ណ្ឌ ៣ នៃប្រការ ២ ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភជូន ដូចតទៅ :

-ថ្នាក់ទី១ ត្រូវបានទទួលចំនួន ១២ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ

-ថ្នាក់ទី២ ត្រូវបានទទួលចំនួន ១០ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ

-ថ្នាក់ទី៣ ត្រូវបានទទួលចំនួន ០៨ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ

-ថ្នាក់ទី៤ ត្រូវបានទទួលចំនួន ០៦ខែ នៃអតីតប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ ។

## ជំពូក២

## នីតិវិធីអនុវត្ត

**ប្រការ៤:** មូលដ្ឋានប្រាក់ដើម្បីគណនា ផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូង ជូនជនពិការត្រូវផ្អែកលើ លិខិតផ្តត់ផ្គង់ហិរញ្ញវត្ថុ ឬតារាងបញ្ជាក់ប្រាក់បៀវត្សប្រចាំខែ របស់អង្គភាពដើមឬតារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមជនពិការដែលត្រូវទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ភ្ជាប់ជាមួយសេចក្តីសម្រេចឬប្រកាសទទួលស្គាល់ជនពិការ របស់ក្រសួងទទួលបន្ទុកវិស័យអតីតយុទ្ធជន។

**ប្រការ៥:** ករណីលិខិត តារាងបញ្ជាក់ប្រាក់ ឬ តារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមជនពិការ ភ្ជាប់ជាមួយសេចក្តីសម្រេច ឬ ប្រកាសទទួលស្គាល់នោះ មានការខូច ឬបាត់បង់ ដោយប្រការផ្សេងៗនោះ អាចប្រើប្រាស់បញ្ជី បើកប្រាក់ឧបត្ថម្ភប្រចាំខែ របស់ជនពិការ ។

**ប្រការ៦:** ជនពិការដែលមានសេចក្តីសម្រេច ឬ ប្រកាសទទួលស្គាល់ របស់អតីត ក្រសួងយុទ្ធជនពិការ សង្គមកិច្ច ក្រសួងការងារ និងសង្គមកិច្ច មុនខែកញ្ញា ឆ្នាំ ១៩៩២ ត្រូវអនុវត្តតាមបញ្ជីបើក ប្រាក់ឧបត្ថម្ភប្រចាំខែ ចាប់ពីខែ កញ្ញាឆ្នាំ ១៩៩២ តមក។

**ប្រការ៧:** របៀបគណនាប្រាក់ឧបត្ថម្ភមួយលើកដំបូង ជូនជនពិការប្រភេទ ក ត្រូវអនុវត្តដូចខាងក្រោម :

១-ចំពោះជនពិការ ដែលមានលិខិតផ្តត់ផ្គង់ហិរញ្ញវត្ថុ ឬតារាងបញ្ជាក់ប្រាក់បៀវត្សប្រចាំខែ ត្រូវបូកសរុបប្រាក់បៀវត្សក្នុងលិខិតផ្តត់ផ្គង់ហិរញ្ញវត្ថុ ឬ តារាងបញ្ជាក់ប្រាក់បៀវត្សនោះ គុណនឹងចំនួនខែ នៃគោលរបបឧបត្ថម្ភជនពិការ ដូចមានកំណត់ក្នុងវាក្យខ័ណ្ឌ ១ ឬ ៣ ឬ ៤ នៃប្រការ ៣ ដូចតទៅ :

ក-របៀបគិតប្រាក់ឧបត្ថម្ភតាមវាក្យខ័ណ្ឌ ១

-ថ្នាក់ទី១ ប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ គុណនឹងចំនួន ៦ខែ

-ថ្នាក់ទី២ ប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ គុណនឹងចំនួន ៤ខែ

-ថ្នាក់ទី៣ ប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ គុណនឹងចំនួន ៣ខែ

-ថ្នាក់ទី៤ ប្រាក់បៀវត្សសរុបប្រចាំខែ របស់ជនពិការ គុណនឹងចំនួន ២ខែ

ខ-របៀបគិតប្រាក់ឧបត្ថម្ភតាមវាក្យខ័ណ្ឌ ៣

-ថ្នាក់ទី១ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ៦ខែ

-ថ្នាក់ទី២ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ៥ខែ

-ថ្នាក់ទី៣ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ៤ខែ

-ថ្នាក់ទី៤ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ៣ខែ

គ-របៀបគិតប្រាក់ឧបត្ថម្ភតាមវាក្យខ័ណ្ឌ ៤

-ថ្នាក់ទី១ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ១២ខែ

-ថ្នាក់ទី២ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ១០ខែ

-ថ្នាក់ទី៣ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ០៨ខែ

-ថ្នាក់ទី៤ ប្រាក់បៀវត្សសរុបប្រចាំខែចុងក្រោយ របស់ជនពិការ គុណនឹងចំនួន ០៦ខែ

២-ចំពោះជនពិការ ដែលយកបញ្ជីបើកប្រាក់ឧបត្ថម្ភប្រចាំខែ របស់ជនពិការមកគណនា ត្រូវអនុវត្តដូចតទៅ :

ក-ជនពិការ ដែលស្ថិតក្នុងប្រភេទ ក ខ គ វាក្យខ័ណ្ឌ ១ នៃប្រការ ២ ត្រូវយកប្រាក់ឧបត្ថម្ភ គោលនយោបាយ សរុបប្រចាំខែរបស់ជនពិការ ដកប្រាក់ជំនួយមុខរបួសជម្ងឺ និងបើជនពិការថ្នាក់ទី ១ ត្រូវដកបន្ថែមប្រាក់ឧបត្ថម្ភអ្នកបំរើ គុណនឹងចំនួនខែ នៃគោលរបបឧបត្ថម្ភជនពិការ ដូចកំណត់ក្នុងវាក្យខ័ណ្ឌ ១ នៃប្រការ ៣ ដូចខាងក្រោម :

-ថ្នាក់ទី១=ប្រាក់ឧបត្ថម្ភគោលនយោបាយសរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ ដកប្រាក់ឧបត្ថម្ភអ្នកបំរើ គុណនឹងចំនួន ៦ ខែ

-ថ្នាក់ទី២=ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ៤ ខែ

-ថ្នាក់ទី៣=ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ៣ ខែ

-ថ្នាក់ទី៤=ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ២ខែ ។

ខ-ជនពិការ ជាអតីតមន្ត្រី ភូមិ ឃុំ កងសេនាជន និងប្រជាជន ស្ថិតក្នុងប្រភេទ ឃវាក្យខ័ណ្ឌ ១នៃប្រការ ២ត្រូវយកប្រាក់ជំនួយមុខរបួសជម្ងឺប្រចាំខែ គុណនឹង ១០០ ចែកនឹងកំរិតភាគរយ នៃប្រាក់ឧបត្ថម្ភជនពិការ បូកនឹងប្រាក់បន្ថែមភាគរយ គុណនឹងចំនួនខែ នៃគោលរបបឧបត្ថម្ភជនពិការ ដូចមានកំណត់ក្នុងវាក្យខ័ណ្ឌ ២ នៃប្រការ ៣ ដូចតទៅ :

-ជនពិការថ្នាក់ទី១= ( ប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹង ១០០ / ១០០ ) បូកជាមួយប្រាក់បន្ថែមភាគរយ គុណនឹងចំនួន ៦ខែ

-ជនពិការថ្នាក់ទី២= ( ប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹង ១០០ / ៨០ ) បូកជាមួយប្រាក់បន្ថែមភាគរយ គុណនឹងចំនួន ៤ខែ

-ជនពិការថ្នាក់ទី៣= ( ប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹង ១០០ / ៦០ ) បូកជាមួយប្រាក់បន្ថែមភាគរយ គុណនឹងចំនួន ៣ខែ

-ជនពិការថ្នាក់ទី៤= ( ប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹង១០០ / ៤០ ) បូកជាមួយប្រាក់បន្ថែមភាគរយ គុណនឹងចំនួន ២ខែ ។

៣-ចំពោះជនពិការស្ថិតក្នុងវាក្យខ័ណ្ឌ២នៃប្រការ ២ ត្រូវយកប្រាក់ឧបត្ថម្ភ គោលនយោបាយសរុបប្រចាំខែ របស់ជនពិការ ដកប្រាក់ជំនួយមុខរបួសជម្ងឺ និងបើជនពិការថ្នាក់ទី ១ ត្រូវដកបន្ថែមប្រាក់ឧបត្ថម្ភអ្នកបំរើ គុណនឹងចំនួនខែ នៃគោលរបបឧបត្ថម្ភជនពិការ ដូចមានកំណត់ក្នុងវាក្យខ័ណ្ឌ ៣ នៃប្រការ ៣ ដូចតទៅ :

-ថ្នាក់ទី១ ប្រាក់ឧបត្ថម្ភគោលនយោបាយសរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ ដកប្រាក់ឧបត្ថម្ភអ្នកបំរើ គុណនឹង

ចំនួន០៦ខែ

-ថ្នាក់ទី២ ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ០៥ខែ

-ថ្នាក់ទី៣ ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ០៤ខែ

-ថ្នាក់ទី៤ ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ០៣ខែ ។

៤-ចំពោះជនពិការស្ថិតក្នុងវាក្យខ័ណ្ឌ ៣នៃប្រការ ២ត្រូវយកប្រាក់ឧបត្ថម្ភ គោលនយោបាយសរុបប្រចាំខែ របស់ជនពិការ ដកប្រាក់ជំនួយមុខរបួសជម្ងឺ និងបើជនពិការថ្នាក់ទី ១ ត្រូវដកបន្ថែម ប្រាក់ឧបត្ថម្ភអ្នកបំរើ គុណនឹងចំនួនខែ នៃគោលរបបឧបត្ថម្ភជនពិការ ដូចមានកំណត់ក្នុងវាក្យខ័ណ្ឌ ៤ នៃប្រការ ៣ ដូចតទៅ :

-ថ្នាក់ទី១ ប្រាក់ឧបត្ថម្ភគោលនយោបាយសរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ ដកប្រាក់ឧបត្ថម្ភអ្នកបំរើ គុណ និង ចំនួន១២ខែ

-ថ្នាក់ទី២ ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ១០ខែ

-ថ្នាក់ទី៣ ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ០៨ខែ

-ថ្នាក់ទី៤ ប្រាក់ឧបត្ថម្ភគោលនយោបាយ សរុបប្រចាំខែ ដកប្រាក់ជំនួយមុខរបួសជម្ងឺ គុណនឹងចំនួន ០៦ខែ ។

## ជំពូក៣

## ការបំពេញបែបបទនីតិការសម្រេចផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការ

**ប្រការ៥:** ប្រាក់ឧបត្ថម្ភមួយលើកដំបូង របស់ជនពិការ ត្រូវកំណត់ និងសម្រេចដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

នាយកដ្ឋាន សោធនអតីតយុទ្ធជន មានភារកិច្ចពិនិត្យបំពេញបែបបទ និងលើកជាមតិជូន ថ្នាក់ដឹកនាំក្រសួងពិនិត្យសម្រេច ។

**ប្រការ៦:** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រុង ត្រូវធ្វើជាសំណើ សុំការសម្រេចពីថ្នាក់ដឹកនាំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយភ្ជាប់មកជាមួយនូវ :

១-បញ្ជីរាយនាមជនពិការ ដែលត្រូវទទួលប្រាក់ជំនួយឧបត្ថម្ភ (តាមគំរូណែនាំ ) ចំនួន២ច្បាប់

២-តារាងបើកប្រាក់ឧបត្ថម្ភប្រចាំខែ ចំនួន ២ច្បាប់ ក្នុងនោះ

-តារាងបើកប្រាក់ឧបត្ថម្ភដើមដំបូង ចំនួន១ច្បាប់

-តារាងបើកប្រាក់ឧបត្ថម្ភប្រចាំខែបច្ចុប្បន្ន ចំនួន ១ ច្បាប់

៣-ត្រូវលើកគំរោងថវិកា ស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានទទួលប្រកាស ផ្តល់ប្រាក់ឧបត្ថម្ភ១លើកដំបូងជូនជនពិការ ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

៤-នៅពេលមានសាច់ប្រាក់គ្រប់គ្រាន់ តាមចំនួនជនពិការ ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ត្រូវធ្វើសេចក្តីជូនដំណឹង ដល់ជនពិការ ដោយកំណត់ទីកន្លែង និងពេលវេលាឱ្យបានច្បាស់លាស់ ព្រមទាំងជូនដំណឹងមកក្រសួង ដើម្បីចាត់មន្ត្រីជំនាញ

ផ្ទាល់ និងពាក់ព័ន្ធ ចូលរួមពិនិត្យការបើកផ្តល់ តាមគោលការណ៍។

## ជំពូក៤

## អវសានប្បញ្ញត្តិ

**ប្រការ១០:**បទបញ្ញត្តិទាំងឡាយណា ផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១:**ប្រកាសនេះ មានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

<u>ចម្លងជូន</u>

ទីស្តីការគណៈរដ្ឋមន្ត្រី

ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សាលាខេត្ត ក្រុង

ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

*ខេត្ត-ក្រុង.......................................*

*លេខ:...........................................*

**ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង........**

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**កម្មវត្ថុ:** សំណើសុំពិនិត្យ និងសម្រេចផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការប្រភេទ " ក " ចំនួន...........................នាក់

**យោង:** ប្រកាសស្តីពីនីតិវិធីកំណត់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនជនពិការលេខ: ១៥៣ សអយ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា : ជនពិការប្រភេទ " ក " ចំនួន...................................នាក់ ដូចមានរាយនាម ក្នុងតារាងឧបសម្ព័ន្ធ នៃបញ្ជីរាយនាមជនពិការ ភ្ជាប់ពុំទាន់ បានទទួល ប្រាក់ឧបត្ថម្ភ មួយលើក ដំបូងតាម គោលការណ៍កំនត់នៅឡើយទេ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាប និង សម្រេចដ៏ខ្ពង់ខ្ពស់

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដោយស្មោះស្ម័គ្ររបស់ខ្ញុំ

ធ្វើនៅថ្ងៃទី................ខែ.................ឆ្នាំ២០០...

**ប្រធានមន្ទីរ**

***សូមជូនភ្ជាប់***

*-តារាងបើកប្រាក់ឧបត្ថម្ភដើមដំបូងចំនួន ១ ច្បាប់*

*-តារាងបើកប្រាក់ឧបត្ថម្ភប្រចាំខែបច្ចុប្បន្នចំនួន ១ ច្បាប់*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

*ខេត្ត-ក្រុង*.....................................

*លេខ:*..........................................

**<u>តារាងឧបសម្ព័ន្ធនៃបញ្ជីរាយនាមជនពិការប្រភេទ ក ត្រូវទទួលប្រាក់ឧបត្ថម្ភ</u>**

**<u>មួយលើកដំបូង</u> ខេត្ត..................**

| ល.រ | ឈ្មោះជនពិការ | ថ្នាក់ពិការ | ទីលំនៅ ( ភូមិ ឃុំ ស្រុក ) | ប្រាក់មួយលើកដំបូង | | | យោងប្រកាសទទួលស្គាល់ |
|---|---|---|---|---|---|---|---|
| | | | | ប្រាក់បៀវត្សរ៍សរុប | ចំនួនខែ | ប្រាក់សរុប | |
| | <u>ថ្នាក់ទី I</u> | | | | | | |
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| | <u>ថ្នាក់ទី II</u> | | | | | | |
| 4 | | | | | | | |
| 5 | | | | | | | |
| | <u>ថ្នាក់ទី III</u> | | | | | | |
| 6 | | | | | | | |
| 7 | | | | | | | |
| | <u>ថ្នាក់ទី IV</u> | | | | | | |
| 8 | | | | | | | |
| 9 | | | | | | | |
| | | | | | | | |

សរុបចំនួន...............នាក់ សរុបប្រាក់ ..................................................

បានពិនិត្យត្រឹមត្រូវ និង ឯកភាព

ធ្វើនៅថ្ងៃទី.........ខែ..........ឆ្នាំ២០០...

ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ធ្វើនៅថ្ងៃទី..........ខែ.........ឆ្នាំ២០០....

ប្រធានការិយាល័យអតីតយុទ្ធជន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ : ៩១៣/...ចក

រាជធានីភ្នំពេញ, ថ្ងៃទី...១០...ខែ...មីនា...ឆ្នាំ២០០៦

# ប្រកាស

# ស្តីពី

# ការកំណត់តាំងបៀវត្សរ៍និងប្រាក់ឧបត្ថម្ភបន្ថែម ជូនកងកម្លាំងបំពេញបេសកកម្មបោសសំអាតមីននៅប្រទេសស៊ូដង់

## រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកត / ០១៩៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- យោង Summary of MOU-negotiations with Cambodia ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥
- យោងលិខិតចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់គណៈកម្មាធិការសំរបសំរួលកិច្ចការបញ្ជូនកម្លាំងចូលរួមរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- យោងចំណារឯកភាព ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**ប្រការ ១** : ប្រាក់បៀវត្សរ៍និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់អង្គការសហប្រជាជាតិ ត្រូវបានផ្តល់ជូនតែក្នុងអំឡុងពេលដែលកងកំលាំងបានទៅបំពេញបេសកកម្មបោសសំអាតមីន នៅប្រទេសស៊ូដង់ ដោយត្រូវផ្តល់បន្ថែមលើប្រាក់បៀវត្សរ៍

និងគោលរបបផ្សេងៗទៀត ដែលមានបច្ចុប្បន្នរបស់កងទ័ព ។

**ប្រការ ២** : ប្រាក់ខែឯកត្តសុទ្ធសាធរបស់កងកំលាំងដែលទៅបំពេញបេសកកម្មបោសសំអាតមីននៅប្រទេសស៊ូដង់ ដែលបានមកពីការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ត្រូវបានកំណត់តាមមុខតំណែងដូចខាងក្រោម ÷

| ល.រ | មុខតំណែង<br>និងថ្នាក់ប្រហាក់ប្រហែល | ក្របខ័ណ្ឌ<br>ត្រូវទទួល | កាំប្រាក់បៀវត្សរ៍<br>ប្រចាំខែម្នាក់ៗ (USD) |
|---|---|---|---|
| ១ | មេបញ្ជាការ កងអនុសេនាធំ | ១នាក់ | 1,140.00 |
| ២ | មេបញ្ជាការរង កងអនុសេនាធំ<br>នាយទាហានសំរបសំរួល<br>នាយទាហានគ្រប់គ្រងភស្តុភារ-ហិរញ្ញវត្ថុ | ៣នាក់<br>១នាក់<br>១នាក់ | 1,090.00 |
| ៣ | មេបញ្ជាការ កងអនុសេនាតូច<br>ប្រធានផែនការនិងសិក្សាគំរោង<br>ប្រធានឃោសនានិងត្រួតពិនិត្យ<br>វេជ្ជបណ្ឌិត | ៤នាក់<br>១នាក់<br>១នាក់<br>១នាក់ | 1,070.00 |
| ៤ | មេបញ្ជាការរង កងអនុសេនាតូច<br>ប្រធានក្រុមកំទេច<br>ពេទ្យមធ្យម | ៦នាក់<br>៤នាក់<br>៣នាក់ | 1,040.00 |
| ៥ | បុគ្គលិកឯកទេស | ១០៩នាក់ | 1,020.00 |

**ប្រការ ៣** : ប្រាក់ឧបត្ថម្ភបន្ថែមប្រចាំខែសំរាប់កងកំលាំង ត្រូវបានកំណត់ស្មើៗគ្នាដូចខាងក្រោម ÷

| ល.រ | បរិយាយប្រាក់ឧបត្ថម្ភ | ចំនួនប្រាក់<br>(USD) | សេចក្តីផ្សេងៗ |
|---|---|---|---|
| **ក** | **<u>សំរាប់យោធិនគ្រប់រូប</u>** | | |
| ១ | ប្រាក់សំលៀកបំពាក់ | 68.00 | |
| ២ | ប្រាក់អាហារ | 28.88 | អ.ស.ប ផ្តល់ជាម្ហូប |
| ៣ | ប្រាក់សំរាប់ពេលវិស្សមកាល | 12.25 | បើកជូន៦ខែម្តង |
| ៤ | ប្រាក់ហោប៉ៅ | 38.40 | |
| ៥ | ឧបត្ថម្ភហ្វឹកហ្វឺន | 5.00 | |
| ៦ | ប្រាក់ធានារ៉ាប់រង អាយុជីវិត(ពលី) | | កំណត់ផ្តល់ដោយ-អ.ស.ប |
| ៧ | ប្រាក់ធានារ៉ាប់រង ពិការ | | កំណត់ផ្តល់ដោយ-អ.ស.ប |
| ៨ | ព្យាបាលជម្ងឺ | | កំណត់ផ្តល់ដោយ-អ.ស.ប |
| **ខ** | **<u>សំរាប់គចឯកទេស</u>** | | |
| ១ | ប្រាក់ឧបត្ថម្ភជំនាញ | 30.30 | (ផ្តល់ជារួម១០%នៃកងកំលាំង) |

**ប្រការ ៤**: រាល់ការផ្ទេរ ឬផ្ញើប្រាក់របស់កងកំលាំងម្នាក់ៗ ត្រូវធ្វើឡើងតាមរយៈធនាគារ ហើយការចំណាយលើសេវាទាំងនោះ គឺជាបន្ទុករបស់សាមីខ្លួនជាម្ចាស់ប្រាក់ ។

**ប្រការ ៥** : អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ នាយក នាយកដ្ឋានបុគ្គលិក បណ្តាស្ថាប័ន និងកងឯកភាពដែលមានការពាក់ព័ន្ធ ត្រូវសហការអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីពេលដែលអង្គការសហប្រជាជាតិបានផ្តល់ប្រាក់សំរាប់ឧបត្ថម្ភដល់កងកម្លាំងដែលត្រូវបំពេញបេសកកម្ម ។

រដ្ឋមន្ត្រី

នាយឧត្តមសេនីយ៍ ទៀ-បាញ់

**ផ្ញើជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការសំរបសំរួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទៀ បាញ់
- ដូចប្រការ ៥

(ដើម្បីជូនជ្រាប និងសហការអនុវត្ត)

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៧៨ ពណ.នគក

ភ្នំពេញថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៦

បានចូល
ថ្ងៃទី ២៤ ខែ ៤ ឆ្នាំ 20០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ុង ម៉ូតូសាយយ៉ល គ្រុប**
**UNG MOTORCYCLE GROUP Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8292/05P** ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **អ៊ុង វណ្ណះជៀន** ប្រធានក្រុមប្រឹក្សាភិបាល
លោក **អ៊ុង វណ្ណារ៉េត** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២0000000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១២ B ផ្លូវលេខ ២០២ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ៍ អាហ័រណ៍ទំនិញគ្រប់ប្រភេទ ពិសេស ទិញ លក់ ជួសជុល កែលំអ តុបតែងគ្រឿងនិងតម្លើងម៉ូតូថ្មីគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស និងដឹកជញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ពិសេសរោងចក្រផលិតម៉ូតូ

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

ង៉ិត ប៊ុន

**<u>ចំលងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ [illegible] ពណ.នគក

ភ្នំពេញថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ ២០០៦

លិខិតបញ្ជាក់ (ថ្ងៃទី [illegible] ខែ ៣ ឆ្នាំ២០០៦)

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ជំរាបមក**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលិកលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ភ្លន់ សុផល្លា ខូ អិលធីឌី**
**PLUN SOPHALA CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8286/ 05P ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :
- លោក **ភ្លន់ ផល្លា** ប្រធានក្រុមប្រឹក្សាភិបាល
- លោក **សួន សុខជាតិ** អភិបាល
- លោកស្រី **ម៉ៃ ចន្ថា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិឬស្សីក្រោក ឃុំឬស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកការបរទេសសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាកម្មនាំជូនអតិថិជនទៅក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម [illegible]
-បោះពុម្ព [illegible]

ក្រសួងពាណិជ្ជកម្ម

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញទីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ.ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គីម ស៊ីថន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តបន្ទាយមានជ័យ
- មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០១៨ ពណ.ឧនក

បានឃើញសម្រេច
ថ្ងៃទី២៤ ខែ 3 ឆ្នាំ2006

ភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **វើលវ៉ាយដ៍ ស៊ីបភីង ខូ អិលធីឌី** |
| | | **WORLDWIDE SHIPPING Co.,Ltd.** |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : | **Co. 2700/05E** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ |
| មានទ្រង់ទ្រាយជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត |
| ២- អភិបាលក្រុមហ៊ុន | : | លោក **MAN YUET CHENG WONG** ប្រធានក្រុមប្រឹក្សាភិបាល |
| | | លោក **ម៉ុ វឌ្ឍា** អភិបាល |
| ៣- ដើមទុនក្រុមហ៊ុន | : | ចំនួន ២០.០០០.០០០ រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | ផ្ទះលេខ ២១ ផ្លូវលេខ ៣២២ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណកម្មទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ |
| | | -ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ |
| | | -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ |
| | | -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ |
| | | -បើកសាលារៀន |
| | | -សេវាយកក់រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម |
| | | -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហកម្ម |
| | | -សេវាផ្សាយពាណិជ្ជកម្ម |
| | | -បោះពុម្ពផ្សាយ |
| | | -ផលិតខ្សែភាពយន្តវីដេអូ CD |
| | | -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនទំនិញនិងចែកចាយទំនិញ |
| | | -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ |
| | | -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត |
| | | -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ |
| | | -វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម |

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៨៣ ពណ.នគក

ភ្នំពេញថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០៦

ចុះបញ្ជី
ថ្ងៃទី ២៤ ខែ ១ ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

| | |
|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : **ធី ជេ អេច ខ្មែរ ខបភើរេសិន លីមីធីត**<br>**TJ H KHMER CORPORATION LIMITED.** |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : **Co. 2710/06E** ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៦ |
| មានទ្រង់ទ្រាយជា | : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត |
| ២- អភិបាលក្រុមហ៊ុន | : លោក **LEE TAE HWAN** |
| ៣- ដើមទុនក្រុមហ៊ុន | : ចំនួន ២.000.000.000 រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : ផ្ទះលេខ ៩២ K មហាវិថីសហព័ន្ធរុស្ស៊ី (១១០) សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : -ជួលអចលនទ្រព្យ -សេវាយកកំរៃជើងសារលើការដឹកជញ្ជូន<br>-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ - សិក្សាគំរោងប្លង់និងគូរប្លង់គ្រប់ប្រភេទ<br>-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត សួនកំសាន្ត ទីលានវាយកូនគោល<br>-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ<br>-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ<br>-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ<br>-បើកសាលារៀន<br>-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះនិងផ្តល់យោបល់លើផ្នែកមិញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្តវីដេអូ CD |

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៤៥ ពណ.នគក

ភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៦

លិខិតចូល
ថ្ងៃទី២៤ ខែ ៦ ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

